ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ១១ លេខ ៤

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

កសវ



Work Activities

ប្រចាំខែមេសា ឆ្នាំ២០១៨



# មាតិកា


| ល.រ | បរិយាយ | លេខទំព័រ |
|---|---|---|
| I- | កិច្ចប្រជុំជំនាញបច្ចេកទេស | |
| | ១- សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីសម្រួលការផលិតស្នាដៃភាពយន្តក្នុងព្រះរាជាណាចក្រកម្ពុជា | ១-២ |
| | ២- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា។ | ៣-៤ |
| II- | កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែមីនា ឆ្នាំ២០១៨ | ៥-១២ |
| III- | សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១៨ | ១៣-១៥ |

## ១- សេចក្តីព្រាងសេចក្តីសម្រេចស្តីពី

## ការបង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីសម្រួលការផលិតស្នាដៃភាពយន្ត ក្នុងព្រះរាជាណាចក្រកម្ពុជា



កាលពីថ្ងៃព្រហស្បតិ៍១៣កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃ២៩ ខែមីនា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ផៃ សុខខេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីសម្រួលការផលិតស្នាដៃភាពយន្តក្នុងព្រះរាជាណាចក្រកម្ពុជា** ដោយមានការអញ្ជើញចូលរួមពី សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីសម្រួលការផលិតស្នាដៃភាពយន្តក្នុងព្រះរាជាណាចក្រកម្ពុជា គឺជាលទ្ធផលនៃការអនុវត្តក្របខណ្ឌគតិយុត្តរបស់រាជរដ្ឋាភិបាល ដើម្បីគាំទ្រគោលនយោបាយជាតិស្តីពីវប្បធម៌ និងដើម្បីគាំទ្រជំរុញការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្ត។

ដើម្បីពង្រឹងការគ្រប់គ្រងវិស័យភាពយន្តនៅកម្ពុជា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានរៀបចំតាក់តែង កែសម្រួលអនុក្រឹត្យស្តីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈ ភាពយន្ត វិដេអូ ទៅជាអនុក្រឹត្យស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្តវិញ ក្នុងគោលបំណងឆ្លើយតបទៅនឹងការវិវត្តន៍រីកចម្រើនរបស់សង្គមជាតិ និងបច្ចេកវិជ្ជាដែលអនុក្រឹត្យនេះត្រូវបាន សម្តេចនាយករដ្ឋមន្ត្រី ចុះហត្ថលេខាដាក់ឲ្យប្រើប្រាស់កាលពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៦ កន្លងទៅ។ នៅក្នុងសារនៃអនុក្រឹត្យនេះ ត្រង់ជំពូកទី៣ មាត្រ១០ បានចែងពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្រួលការផលិតភាពយន្តក្នុងព្រះរាជាណាចក្រកម្ពុជា។

ដោយពិនិត្យឃើញនូវភាពចាំបាច់ក្នុងការពង្រឹងការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្តឲ្យមានប្រសិទ្ធភាព និងដើម្បីរួមចំណែកលើកកម្ពស់ការទាក់ទាញផលិតករភាពយន្តឲ្យប្រើប្រាស់សក្តានុពលសម្បត្តិបេតិកភណ្ឌវប្បធម៌ និងធម្មជាតិរបស់ជាតិក្នុងការផលិតស្នាដៃភាពយន្តស្របតាមខ្លឹមសារនៃគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានរៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីសម្រួលការផលិតស្នាដៃភាពយន្តក្នុងព្រះរាជាណាចក្រកម្ពុជា[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងសេចក្តីសម្រេចនេះ ហើយបានសម្រេចកែសម្រួលទម្រង់ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ៕



(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីសម្រួលការផលិតស្នាដៃភាពយន្តក្នុងព្រះរាជាណាចក្រកម្ពុជា។

# ២-សេចក្តីព្រាងអនុក្រឹត្យស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា

កាលពីថ្ងៃពុធ ១១កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃ២៥ ខែមេសា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តមសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំកិច្ចប្រជុំជំនាញបច្ចេកទេស ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា** ដោយមានការអញ្ជើញចូលរួមពីសមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី តំណាងក្រសួងសេដ្ឋកិច្ច និង តំណាងគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា។




សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា ត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា ក្នុងគោលបំណងកំណត់ពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា ដែលសរសេរអក្សរកាត់ថា គ.ជ.ប.ក. និងជាភាសាអង់គ្លេស NATIONAL PARALYMPIC COMMITTEE OF CAMBODIA សរសេរជាអក្សរកាត់ NPCC។ គណៈកម្មាធិការនេះមានតួនាទីភារកិច្ចដូចខាងក្រោម៖

- ត្រូវដឹកនាំ គ្រប់គ្រង និងទទួលខុសត្រូវផ្តាច់មុខលើវិស័យកីឡារបស់ជនពិការកម្ពុជា
- ត្រូវធ្វើជាតំណាងឲ្យព្រះរាជាណាចក្រកម្ពុជាលើវិស័យកីឡាជនពិការកម្ពុជាលើឆាកជាតិនិងអន្តរជាតិ
- ត្រូវទទួលខុត្រូវក្នុងការរៀបចំអាស៊ានប៉ារ៉ាហ្គេមលើកទី១២នាឆ្នាំ២០២៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះឲ្យទទួលបានជោគជ័យ
- ត្រូវរៀបចំគណៈកម្មាធិការប្រតិបត្តិដឹកនាំរៀបចំអាស៊ានប៉ារ៉ាហ្គេមលើកទី១២ នាឆ្នាំ២០២៣
- ត្រូវគ្រប់គ្រងសហព័ន្ធ និងក្លឹបកីឡាជនពិការ
- ត្រូវគ្រប់គ្រង និងដឹកនាំ កីឡាជនពិការ ក្នុងការចូលរួមព្រឹត្តិការណ៍ និងការប្រកួតកីឡាផ្សេងៗ របស់ជនពិការនៅក្នុងប្រទេស និងក្រៅប្រទេស ជាកម្រិតជើងឯក ជាកម្រិតជាតិ និងជាកម្រិតអន្តរជាតិ

- ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត និងបែបបទអនុវត្តបទដ្ឋានកីឡាអន្តរជាតិដែលពាក់ព័ន្ធ
- ត្រូវធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ អាជ្ញាធរ និងអង្គការកីឡាជាតិ វិស័យឯកជន
- ត្រូវធ្វើកិច្ចសហប្រតិបត្តិការជាមួយសហព័ន្ធកីឡាជនពិការអាស៊ាន គណៈកម្មាធិការប៉ារ៉ាឡាំពិកអាស៊ី គណៈកម្មាធិការប៉ារ៉ាឡាំពិកអន្តរជាតិ និងស្ថាប័នកីឡាអន្តរជាតិផ្សេងៗទៀត
- ត្រូវបំពេញបែបបទស្នើសុំជាសមាជិកពេញសិទ្ធិរបស់សហព័ន្ធកីឡាជនពិការអាស៊ាន គណៈកម្មាធិការប៉ារ៉ាឡាំពិកអាស៊ី និងគណៈកម្មាធិការប៉ារ៉ាឡាំពិកអន្តរជាតិ
- ត្រូវបំផុស ផ្សព្វផ្សាយ អប់រំ គុណតម្លៃកីឡា អត្ថប្រយោជន៍កីឡា និងទស្សនាទានកីឡានៃឥទ្ធិពលកីឡាប៉ារ៉ាឡាំពិក
- ត្រូវកៀរគរធនធានហិរញ្ញវត្ថុ និងជំនួយផ្សេងៗពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ
- ត្រូវរៀបចំបូកសរុបរបាយការណ៍វឌ្ឍនភាពការងារប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល និងស្ថាប័នកីឡាប៉ារ៉ាឡាំពិកអន្តរជាតិ។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ៕



# II- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែមីនា ឆ្នាំ២០១៨



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំខែមីនា ឆ្នាំ២០១៨** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង នៃ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែមីនា ឆ្នាំ២០១៨សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,០៤% ធៀបនឹងខែមុន និងកើនឡើង២,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| ក្រុមទំនិញ: | | មុខទំនិញ: | |
|---|---|---|---|
| ភោជនីយដ្ឋាន: | +៧,៥% | ឧស្ម័ន | +៦,៩% |
| ទំនិញ និងសេវាកម្មផ្សេងៗ | +៣,៦% | ប្រេងសាំង: | +៥,៣% |
| ការដឹកជញ្ជូន: | +២,៥% | ប្រេងម៉ាស៊ូត: | +៤,២% |
| ម្ហូបអាហារ: | +២,២% | ត្រីស្រស់: | +៤,៨% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈផ្សេងទៀត | +១,៣% | សាច់គោ: | +២,៨% |
| សំលៀកបំពាក់ និងស្បែកជើង: | +១,៣% | សាច់ជ្រូក: | +០,៧% |
| សុខាភិបាល: | +១,២% | សាច់មាន់: | +០,៦% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់: | +០,៥% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៦–២០១៨

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា[P] | ឧសភា[P] | មិថុនា[P] | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៨ | ដូចគ្នាឆ្នាំមុន | ២,០% | ២,៣% | ២,៣% | ២,២% | ២,៦% | ២,៩% | | | | | | | |
| | មុន | ០,១% | ០,៤% | ០,០៤% | ០,៣% | ០,២% | ០,៤% | | | | | | | |
| ២០១៧ | ដូចគ្នាឆ្នាំមុន | ៤,៤% | ៤,០% | ៤,២% | ៣,២% | ២,៥% | ២,៣% | ២,៣% | ២,៦% | ២,៧% | ២,១% | ២,៣% | ២,២% | ២,៩% |
| | មុន | ០,៣% | ០,១% | ០,០% | ០,៤% | -០,២% | ០,១% | ០,៣% | ០,៤% | ០,៣% | -០,២% | ០,២% | ០,៤% | |
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ២,៩% | ៣,០% | ៣,៤% | ៣,៦% | ៣,៩% | ៣% |
| | មុន | -០,២% | ០,៤% | -០,២% | ១,៤% | ០,៥% | ០,២% | ០,៣% | ០,២% | ០,៣% | ០,៤% | ០ | ០,៤% | |

**P:** តួលេខខែមេសា ឧសភា និងមិថុនា ឆ្នាំ២០១៨ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ **DECOMPOSITION)**

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្រប់ដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តារាង







១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | មីនា ២០១៨ | កុម្ភៈ២០១៨ | មីនា ២០១៧ | *ប្រភេទ* | មីនា ២០១៨ | កុម្ភៈ ២០១៨ | មីនា ២០១៧ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០០០៛/១$ | ៤០១០៛/១$ | ៤០០៥៛/១$ | **បាត/ដុល្លារ** | ៣១,២៤បាត/១$ | ៣១,៤៥បាត/១$ | ៣៤,៤៩បាត/១$ |
| **៛/បាត** | ១២៨៛/១បាត | ១២៨៛/១បាត | ១១៦៛/១បាត | **ដុង/ដុល្លារ** | ២២៨០៥ដុង/១$ | ២២៧២៧ដុង/១$ | ២២៧៦៥ដុង/១$ |
| **៛/ដុង** | ០,១៧៥៛/១ដុង | ០,១៧៦៛/១ដុង | ០,១៧៦៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែមីនា ឆ្នាំ២០១៨ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១៥០៩,២ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣៧៧,៣ លានដុល្លារ ( *មធ្យមប្រចាំខែ ៩២% នៃផែនការ*) ក្នុងនោះ: ចំណូលចរន្តចំនួន១៤៩៦,៣ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣៧៤,១ លានដុល្លារ ( *មធ្យមប្រចាំខែ ៩៣% នៃផែនការ*) និងចំណូលមូលធនចំនួន១២,៩ប៊ីលានរៀល (តាមតួលេខ រតនាគារជាតិ)។

➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិកើនឡើង ១៣,៦%ប៉ុន្តែថយចុះ១៥,៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៦-២០១៨ (ប៊ីលានរៀល)




➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១៤០៣,២ប៊ីលានរៀលកើនឡើង ១៨,៨% ធៀបនឹងខែមុនប៉ុន្តែ ថយចុះ ១១,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ រតនាគារជាតិ)។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន៩៣,១ប៊ីលានរៀល ថយចុះ៣៦,៧%ធៀបនឹងខែមុន និងថយចុះ ៥២,៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ រតនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខ រតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: +១៣,៣% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+២៩,៩%) | ➢កាស៊ីណូ : +៥៥,៥% | (+១២,១%) |
| | | ➢អាជ្ញាបណ្ណក្នុងស្រុក : +៤៩,៤% | (-៩១,៨%) |
| ➢ ចំណូលពន្ធដារ: +៦៨% (អគ្គនាយកដ្ឋានពន្ធដារ) | (-១០,៨%) | ➢ នេសាទ:+៥៨៦,៥% | (-២៦,៤%) |
| | | ➢សម្បទានរ៉ែ: -៣៣,៦% | (-៣២,២%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: -៨៣,៦% | (-១៣,៨%) |

**២.២. ចំណាយថវិកាជាតិ** :អនុវត្តបាន ១២៧១,៣ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣១៧,៨៣ លានដុល្លារ (*មធ្យមប្រចាំខែ ៦៦% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ១០៣៧,៦ប៊ីលានរៀល (*មធ្យមប្រចាំខែ ៧៣% នៃផែនការ*) និងចំណាយមូលធនមានចំនួន២៣៣,៨ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិកើនឡើង១២,៥%ធៀបនឹងខែមុននិងកើនឡើង១០,៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ:ចំណាយចរន្តកើនឡើង១,៦%ធៀបនឹងខែមុននិងកើនឡើង៩,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៦-២០១៨ (ប៊ីលានរៀល)




**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានអតិរេកចំនួន ២៣៧,៩ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៥៩,៤៧ លានដុល្លារ (តួលេខរតនាគារជាតិ)។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែមីនាឆ្នាំ២០១៨មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន៧៥១៦៤ប៊ីលានរៀល កើនឡើង២,៧%ធៀបនឹងខែមុន និងកើនឡើង ២៤,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង** $M_2$ ក្នុងខែនេះ ជារួមបណ្ដាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ០,៩% និងប្រាក់បញ្ញើជារូបិយបណ្ណ៤,២%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែមីនាឆ្នាំ២០១៨




➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៥,៥% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៤,៥% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៨

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៦,៨% | ១៦,៧% | ១៥,៥% | | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១១,៦% | ១១,៥% | ១១,៣% | | | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែមីនា២០១៨: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន៨៨២៤លានដុល្លារ កើនឡើង០,៥%ធៀបនឹងខែមុន និងកើនឡើង២៣,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ២៧២២៧ ប៊ីលានរៀលកើនឡើង ២,២%ធៀបនឹងខែមុន និងកើនឡើង២៩,១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *មីនា២០១៨* | *កុម្ភៈ២០១៨* | *មីនា២០១៧* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល)<br>ក្នុងនោះ ជារៀល | ៧០៣០០ | ៦៩៣៥៧<br>១៥៩៤ | ៥៨៨៧៨<br>១០១៤ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ១៨០០២ | ១៣៦២៥ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,០៤% | ៥,៩៥% | ៦,៧១% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១២,០៣% | ១២,២៤% | ១៦,០៥% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤២% | ៤,៤៣% | ៤,៤៥% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៤៥% | ១១,៦៥% | ១១,៦៧% |
| អត្រាការប្រាក់កម្ចីជារៀលនៅហត្ថកសិករ | ១៨% | ១៨% | ២៣,៤% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | ១៨% | ១៨% | ២៨,៨% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | ១៦,១% | ១៧% | ២២,៨% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងថាមពល

➡ក្នុងខែមីនា ឆ្នាំ២០១៨ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៤៧,៩៦ពាន់តោន ថយចុះ៥% ធៀបនឹងខែមុនប៉ុន្តែកើនឡើង៤,៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢រ៉ែ និងថាមពល:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៧៣៧,២៣GWHមានការកើនឡើង៨,២%ធៀបនឹងខែមុន និងកើនឡើង២៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន១៦៣,២២GWHមានការ កើនឡើង២៤,៧% ធៀបនឹងខែមុន និងមានការកើនឡើង៧០%ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន៣៤៤,៤GWHមានការថយចុះ៦,៦% ធៀបនឹងខែមុនប៉ុន្តែមានការកើនឡើង៣% ធៀបនឹងខែដូចគ្នាឆ្នាំ មុន អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDC មានចំនួន១៨០,១៧GWHមានការ កើនឡើង២៨% ធៀបនឹងខែមុន និងមានការកើនឡើង២៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន៤៩,៤៣GWHមានការ កើនឡើង២១,៨% ធៀបនឹងខែមុន និងមានការកើនឡើង៩៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ឧស្សាហកម្ម:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៦២៥,៣លានដុល្លារមានការកើនឡើង៨% ធៀបនឹងខែមុន និងកើនឡើង១១,១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន — មីនា២០១៨ | ចំនួន—កុម្ភ:២០១៨ | ចំនួន—មីនា២០១៧ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ១១ | ១៦ | ៨ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៥៥៦ | ១៥៤៥ | ១៥៩៣ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៦ | ១២ | ២០ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ៣០ | ២៥ | ១៨ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន៣៥៦,៣ពាន់ម២កើនឡើង១៥៩%ធៀបនឹងខែមុន ប៉ុន្តែថយចុះ៦២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង១៤០,៦លានដុល្លារកើនឡើង១១០%ធៀបនឹងខែមុន ប៉ុន្តែថយចុះ៧៥%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម២ — មីនា២០១៨ | ពាន់ម២ — កុម្ភ:២០១៨ | ពាន់ម២ — មីនា២០១៧ |
|---|---|---|---|
| ▪ លំនៅឋាន | ១៦០,៨ | ៧៩,៦ | ៦៨៧,៦ |
| ▪ ឧស្សាហកម្ម | ៩៩,០ | ១០,៥ | ៨២,៩ |
| ▪ពាណិជ្ជកម្ម | ៨៧,៥ | ៣១,៣ | ៦៣,៣ |
| ▪ ទេសចរណ៍ | ៧,៨ | ១៥,៥ | ៩៤,៦ |
| ▪ផ្សេងៗ | ០,០ | ០,១ | ០,៥ |
| អនុញ្ញាតសរុប | ៣៥៦,៣ | ១៣៧,៥ | ៩៣០,៦ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺលំនៅដ្ឋាន៤៥,១% និងឧស្សាហកម្ម២៧,៧%នៃផ្ទៃក្រឡាសរុប។

## ➢ការងារ

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់–មីនា ២០១៨ | នាក់–កុម្ភៈ ២០១៨ | នាក់–មីនា ២០១៧ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ១៧៣៧ | ១៥៥២ | ១១០៨ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ១៤៧១២ | ១៥៧៣៥ | ១២៤៨៧ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៩៧៨៨ | ១១០២១ | ៩៩៦៦ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៤៩២៤ | ៤៧១៤ | ២៥២១ |

## ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | មីនា២០១៨ | កុម្ភៈ២០១៨ | មីនា២០១៧ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៣៥៧,៧ | ១១៩,២ | ៩១,០ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ១៦៩,៨ | ៤៣,៣ | ៥៧,៧ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ១១២,៧ (២១,១) | ៧៥,៩ (៧) | ៣៦,៣ (៧,៥) |
| វិស័យទេសចរណ៍ | ៧៥,២ | ០,០ | ០,០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០,០ | ០,០ | ០,០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ២៥,០ | ១៤ | ១៣,០ |
| បង្កើតការងារ (ពាន់នាក់) | ២៧,០ | ១០,៩ | ១២,៥ |

## ➢សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន – មីនា២០១៨ | ចំនួន–កុម្ភៈ២០១៨ | ចំនួន–មីនា២០១៧ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៨៦៧ | ១០៨៤ | ៤១៩ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៩ | ១០ | ២ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | | | ៥១៤ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៩២៩,៨៣ពាន់តោនថយចុះ២៩% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ:

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | |
|---|---|
| ▪ កំពង់ផែភ្នំពេញ:-៦៦% (+១%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង: +២៦,៣% (+៣៧១%) |
| ▪ កំពង់ផែកំពង់សោម:+១៧% (-២%) | (+២%) |
| | ▪ កំពង់ផែឧកញ៉ាម៉ុង: -២៦% |

➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %∆ ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ៥៩.២ | ២០១% | ១៩៥% |
| ក្នុងនោះទទួល | ៧,៤ | ២៣២% | ២២៩% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៣៥៧,៧ | ២០៨% | ១៧៩% |
| ក្នុងនោះទទួល | ១៦៨,៥ | ២០៣% | ១៩៦% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | | | |
| ក្នុងនោះហៅចូល | | | |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | | | |
| ក្នុងនោះហៅចូល | | | |

➢ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %∆ ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ២៣,២ | -១៨% | -៧% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៦៣,២ | -២០% | ៣២% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៨៥៩,០ | -១% | ៣៤% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១៥០,៦ | ៥,៨% | ២២% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៥៧២,១ | ៥% | ២០% |
| ✓ តាមផ្លូវអាកាស | ៣៩៥,១ | ៦% | ៣៦% |
| ✓ តាមផ្លូវគោក និងទឹក | ១៧៧,០ | ៥% | -៥% |

## ៥) ស្ថានភាពជញ្ជូនពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែមីនា ឆ្នាំ២០១៨ មានចំនួន ៤៦៤៣,៨ប៊ីលានរៀល (ស្មើនឹង១១៦០,៩លានដុល្លារ ស.រ.អា.)ថយចុះ៦,៧%ធៀបនឹងខែមុន និងថយចុះ២,៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ :

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %∆ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -៤,៧% | +២,៥% | រថយន្តសរុប (ប៊ី.ល.រ) | +២៧,៣% | +២៣,១% |
| ប្រេងម៉ាស៊ូត | +១៦,៧% | +២៦,៣% | រថយន្តសរុប (គ្រឿង) | -៩,៥% | -៤,៧% |
| ឧស្ម័ន | +២៧,១% | +២៩,៦% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +២៥,១% | +១៥,៦% |
| អគ្គិសនីនាំចូលដោយ | +២៨% | +២៥% | ម៉ូតូ (គ្រឿង) | +៨,៨% | |
| ដែកសំណង់ | -១៦,៦% | -៣២,៨% | អង្ករ | +៤៤,២% | +១៤០,៤% |
| ស៊ីម៉ង់ត៍ | +៨៩,៩% | +៦២,៦% | ផ្លែឈើនិងបន្លែ | -០,៣% | +២៣,៧% |
| គ្រឿងអេឡិចត្រូនិក | +៥៥,៣% | +៣៤១,៨% | ជីនិងថ្នាំកសិកម្ម | +២,៤% | +១៩,៩% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិ | -២៥,៤% | -១៧% |

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែមីនា ឆ្នាំ២០១៨នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | សំណង់អនុញ្ញាតអោយសាងសង់ (ជាផ្ទៃក្រឡា) | ១៥៩% | -៦២% | |
| ២ | សំណង់អនុញ្ញាតអោយសាងសង់ (ជាសាច់ប្រាក់) | ១១០% | -៧៥% | |
| ៣ | ការនាំចូលដែកសំណង់ | -១៦,៦% | -៣២,៨% | |
| ៤ | ការនាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -២៥,៤% | -១៧% | |

## ៧) សេចក្តីសន្និដ្ឋាន

១) ទោះបីជាថ្លៃទំនិញមួយចំនួនមានការកើនឡើងខ្លះក៏និន្នាការអតិផរណា នឹងនៅក្រោមទិសដៅកំណត់ ៥%។

២) ករណីពុលរបស់ប្រជាពលរដ្ឋ ជាបញ្ហាសុខភាពសាធារណៈនៃសង្គមខ្មែរដែលត្រូវយកចិត្តទុកដាក់ ព្រោះថាមានការកើតឡើងជាញឹកញាប់ ឆ្នាំ ២០១៥មាន ៣៣ករណី ឆ្នាំ២០១៦ ១៩ករណី ២០១៧ ៩ករណី និង ២០១៨ មានករណីពុលស្លាប់១៣នាក់និងចូលសម្រាកនៅមន្ទីពេទ្យរាប់រយនាក់ នៅខេត្តក្រចេះ។ មូលហេតុនៃការពុលមានខុសៗគ្នា ក្នុងនោះចំណីអាហារខ្វះអនាម័យឬមានផ្ទុកសារធាតុគីមី ឬវេចខ្ចប់មិនល្អ ឬធ្វើពីសាច់បន្លែដែលខូចគុណភាព ស្រាសដែលបិទមិនត្រូវតាមបទដ្ឋាន ឬស្រាក្លែងក្លាយជាដើម។

៣) ការលាយបន្លំអង្ករនាំចូលជាមួយអង្ករក្នុងស្រុក ជាបញ្ហាចម្បងមួយដែលកើតមានឡើងនាពេលបច្ចុប្បន្ន ធ្វើឲ្យអ្នកប្រើប្រាស់រងគ្រោះ ទាំងគ្រួសារសាមញ្ញ ទាំងក្រុមហ៊ុនអាជីវកម្មដែលប្រើអង្ករឬម្សៅអង្ករសម្រាប់ផលិតទំនិញរបស់ខ្លួន ព្រោះមានផ្ទុកសារធាតុគីមីខ្ពស់។ ការណ៍នេះ តម្រូវឲ្យអង្ករនាំចូលបិទស្លាកប្រទេសផលិតនៅពេលនាំចូលតាមច្រកព្រំដែន៕

## III- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១៨

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៤/១៨ ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ ក្នុងរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសាលមហោស្រពកោះពេជ្រ។ |
| ២ | ០១/០៤/១៨ ម៉ោង១៤:០០នាទី | ចូលរួមក្នុងពិធីប្រកាសប្រធានគណៈកម្មាធិការគណបក្សខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ៣ | ០៣/០៤/១៨ ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រ-ជាន់ខ្ពស់ជូនដល់និស្សិត នៃវិទ្យាស្ថាន វ៉ាន់ដា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៤ | ០៣/០៤/១៨ ម៉ោង១៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីពិសារអាហារសាមគ្គីក្នុងមហាគ្រួសារកីឡាជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសាលមហោស្រពកោះពេជ្រ។ |
| ៥ | ០៧/០៤/១៨ ម៉ោង០៨:០០នាទី | ចូលរួមពិធីសន្និបាតបូកសរុបការងារគណបក្សខេត្តតាកែវ ឆ្នាំ២០១៧ និងទិសដៅភារកិច្ចអនុវត្តបន្តឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ៦ | ០៨/០៤/១៨ ម៉ោង០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយកម្មករនិយោជិត ប្រធានរដ្ឋបាល ប្រធានផ្នែក ប្រធានក្រុម និងជំនួយការ មកពីខេត្តកំពង់ស្ពឺ និងខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសាលមហោស្រពកោះពេជ្រ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | ០៩/០៤/១៨ **ម៉ោង១៥:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសូត្រមន្តចម្រើនព្រះបរិត្ត អបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ និងពិធីជួបជុំសំណេះសំណាលពិសារអាហារសាមគ្គី ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ចិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្ដីទីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ១០/០៤/១៨ **ម៉ោង០៦:៣០នាទី** | ចូលរួមជាមួយ ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងពិធីបើកឲ្យប្រើប្រាស់ជាបណ្តោះអាសន្នគម្រោងរថភ្លើងដឹកអ្នកដំណើរភ្នំពេញ-ព្រលានយន្តហោះអន្តរជាតិភ្នំពេញ នៅស្ថានីយ៍រថភ្លើងភ្នំពេញ។ |
| ៩ | ១០/០៤/១៨ **ម៉ោង១៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីជួបជុំពិសាបាយសាមគ្គីរបស់សមាគមខ្មែរ-ចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលពិព័រណ៍កោះពេជ្រ។ |
| ១០ | ១១/០៤/១៨ **ម៉ោង០៨:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីដាក់ឲ្យដំណើរការជាផ្លូវការនូវ "មូលនិធិគន្ធបុប្ផាកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅទីស្ដីការនាយករដ្ឋមន្ត្រី។ |
| ១១ | ១១/០៤/១៨ **ម៉ោង១០:០០នាទី** | ចូលរួមកិច្ចប្រជុំពិភាក្សាការងារជាមួយ ប្រតិភូក្រសួងពាណិជ្ជកម្មរបស់ភាគីចិន ស្តីពីការថែទាំនិងជួសជុលអគារមិត្តភាពនិងអគារ IT នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ២០/០៤/១៨ **ម៉ោង០៨:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសដាក់ឲ្យអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ និងកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាព៥ឆ្នាំ និងប្រចាំឆ្នាំ២០១៧ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៣ | **២១/០៤/១៨ ម៉ោង០៨:៣០នាទី** | ចូលរួមប្រជុំពិភាក្សាការងារនៅមូលដ្ឋានខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ឋិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | **២២/០៤/១៨ ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយ ប្រធាន អនុប្រធានសាខាគណបក្ស សហជីព កម្មករនិយោជិត និងតំណាងមន្ត្រីរាជការ គ្រូបង្រៀន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសាលមហោស្រពកោះពេជ្រ។ |
| ១៥ | **២៤/០៤/១៨ ម៉ោង១១:០០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ផែន សុខឌ្ឍនោ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | **២៦/០៤/១៨ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែមីនា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | **២៩/០៤/១៨ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបុណ្យវិសាខបូជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅភ្នំព្រះរាជទ្រព្យ ស្រុកពញាឮ ខេត្តកណ្តាល។ |
| ១៨ | **៣០/០៤/១៨ ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់វិញ្ញាបនបត្រ និងសញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់សិក្ខាកាម និងនិស្សិត នៃសាកលវិទ្យាល័យ ធនធានមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានជាតិអប់រំ។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in